Embassy of Sweden
Phnom Penh

USAID
ជំនួយពីពលរដ្ឋអាមេរិក

SOLIDARITY CENTER

ACF FOUNDATION

សម្រាប់ការចេញផ្សាយបន្ទាន់

**សេចក្តីប្រកាសព័ត៌មាន**

# ប្រទេសស៊ុយអែត និងទីភ្នាក់ងារសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិសហរដ្ឋអាមេរិក ផ្តល់មូលនិធិគាំទ្រដល់ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីពង្រឹងសេវាដោះស្រាយវិវាទការងារនៅកម្ពុជា

**រាជធានីភ្នំពេញ(ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០)** - ថ្ងៃនេះ ទីភ្នាក់ងារសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិសហរដ្ឋអាមេរិក និងស្ថានទូតស៊ុយអែតប្រចាំនៅកម្ពុជា បានប្រកាសផ្តល់ជំនួយឥតសំណងដល់មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីពង្រឹងសេវាដោះស្រាយវិវាទការងារនៅកម្ពុជា។

ទីភ្នាក់ងារសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិសហរដ្ឋអាមេរិក ដែលបាននឹងកំពុងផ្តល់ថវិកាគាំទ្រដល់មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលតាំងពីឆ្នាំ២០១៤មក បានបន្តផ្តល់ជំនួយមូលនិធិថ្មីចំនួនទឹកប្រាក់ប្រមាណ ១លាន ៥សែនដុល្លារសហរដ្ឋអាមេរិក សម្រាប់រយៈពេលប្រាំឆ្នាំ ដល់មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល តាមរយៈដៃគូរបស់ខ្លួនគឺមជ្ឈមណ្ឌលសាមគ្គីភាពដែលជាដៃគូយូរអង្វែង និងជាផ្នែកនៃគម្រោងថ្មីមួយរបស់ទីភ្នាក់ងារសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា ស្តីពីសិទ្ធិការងារនៅកម្ពុជា។ ប្រទេសស៊ុយអែតក៏បានផ្តល់មូលនិធិគាំទ្រដល់មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល តាំងពីឆ្នាំ២០១៤មកផងដែរ។ ថ្ងៃនេះ ស្ថានទូតស៊ុតអែត បានចុះហត្ថលេខាផ្តល់មូលនិធិសរុបចំនួន ៥លានក្រូណា (ប្រមាណ៥៣ម៉ឺនដុល្លារសហរដ្ឋអាមេរិក) សម្រាប់អនុវត្តគម្រោងរយៈពេល២ឆ្នាំ (២០២០-២០២១) ដើម្បីលើកកម្ពស់ ប្រព័ន្ធមជ្ឈត្តវិនិច្ឆ័យដោះស្រាយវិវាទការងារដោយអាជ្ញាកណ្តាលដែលអាចជឿជាក់បាន និងប្រកបដោយប្រសិទ្ធិភាព។

ការផ្តល់មូលនិធិទាំងពីរនេះមានគោលបំណងដូចគ្នា គឺដើម្បីធ្វើឱ្យប្រព័ន្ធទំនាក់ទំនងការងារ និងសេវាដោះស្រាយវិវាទការងារនៅក្នុងប្រទេសកម្ពុជាកាន់តែមានប្រសិទ្ធភាព បង្កើនការយល់ដឹងពីក្រុមប្រឹក្សាអាជ្ញាកណ្តាល និងលើកកម្ពស់ជំនាញក្នុងការដោះស្រាយវិវាទការងារទៅដល់កម្មករ និយោជិត និងនិយោជក និងដើម្បីរក្សា និងលើកកម្ពស់សុចរិតភាព និងនិរន្តរភាពរបស់ស្ថាប័នក្រុមប្រឹក្សាអាជ្ញាកណ្តាល។

មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៥ គឺជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយដែលផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងគ្រប់គ្រងទៅដល់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ក្រុមប្រឹក្សាអាជ្ញាកណ្តាល គឺជាស្ថាប័នជាតិឯករាជ្យមួយដែលមានអំណាចដោះស្រាយវិវាទការងាររួមនៅកម្ពុជាតាមច្បាប់ការងារ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ត្រូវបានទទួលស្គាល់ថាជាស្ថាប័នចម្បងជាសារវន្តមួយសម្រាប់ការដោះស្រាយវិវាទការងារនៅកម្ពុជា ដើម្បីជួយឱ្យមានស្ថិរភាពទីផ្សារការងារ និងរួមចំណែកក្នុងការអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ចជាតិ។

**លោក Samuel Hurtig (សាមូអ៊ែល ហ៊ូទីក)** ប្រធានកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិរបស់ប្រទេសស៊ុយអែត ប្រចាំនៅកម្ពុជា មានប្រសាសន៍ថា៖ "ទីផ្សារការងារនៅគ្រប់ប្រទេសទាំងអស់កំពុងតែរីកលូតលាស់ទៅមុខ ហើយត្រូវការសម្របទៅតាមការប្រែប្រួល។ អ្នកផលិតទាំងឡាយ ត្រូវតែបង្កើនគុណភាពទំនិញ

និងរក្សាផលចំណេញដោយថ្លឹងថ្លែងជាមួយនឹងតម្រូវការសិទ្ធិការងារ មានជាអាទិ៍ ស្តង់ដារការងារសមរម្យ និងប្រាក់ឈ្នួលដោយយុត្តិធម៌ សមភាពយេនឌ័រ ក៏ដូចជាបញ្ហាបរិស្ថាន ដែលប៉ះពាល់ដល់ផលិតកម្ម និងលក្ខខណ្ឌការងារនានា។ តួនាទីរបស់រដ្ឋាភិបាល គឺបង្កើតគោលនយោបាយ ដែលធ្វើឱ្យមានការអភិវឌ្ឍទីផ្សារការងារយោងតាមច្បាប់ និងបទដ្ឋានគតិយុត្តនានា។ សហជីពគឺជាតួអង្គសំខាន់ដើម្បីតំណាងឱ្យសិទ្ធិកម្មករ និងគួរត្រូវបានការពារដោយច្បាប់។ យន្តការដោះស្រាយវិវាទការងារដែលអាចជឿជាក់បាន និងឯករាជ្យ គឺជាធាតុផ្សំដ៏ចាំបាច់សម្រាប់ទីផ្សារការងារដែលដំណើរការប្រកបដោយប្រសិទ្ធភាព។ តួនាទីរបស់មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងការដោះស្រាយវិវាទនៅក្នុងទីផ្សារការងារ គឺមានសារៈសំខាន់ណាស់។ ប្រទេសស៊ុយអែត នឹងបន្តជួយគាំទ្រមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលដើម្បីធានាថាក្រុមប្រឹក្សាអាជ្ញាកណ្តាល នឹងបន្តដើរតួនាទីរបស់ខ្លួនដោយឯករាជ្យ និងប្រកបដោយវិជ្ជាជីវៈ។"

**លោក Javier Castano (ហាវ្យ៉ា ខាស្តាណូ)** អនុប្រធានស្តីទីនៃទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ មានប្រសាសន៍ថា៖ "វាគឺជាការសំខាន់ដែលត្រូវថែរក្សាប្រព័ន្ធដោះស្រាយវិវាទការងាររួម ដែលមានអំណាចកាត់សេចក្តី និងដោះស្រាយដោយសន្តិវិធី ដោយស្ថាប័នដែលទាំងខាងកម្មករនិយោជិត និងនិយោជកទទួលស្គាល់ថាមានអព្យាក្រឹតភាព និងមិនលម្អៀង"។ លោក ហាវ្យ៉ា ខាស្តាណូ មានប្រសាសន៍បន្ថែមទៀតថា៖ "នេះគឺជាមូលហេតុ ដែលយើងជ្រើសរើសគាំទ្រដល់តួនាទីស្នូលសំខាន់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងការបង្កើតឡើងនូវបរិយាកាសប្រកបដោយការជឿជាក់សម្រាប់កម្មករនិយោជិត និយោជក និងអ្នកវិនិយោគនានា ជាប្រព័ន្ធដោះស្រាយវិវាទដែលមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ។"

មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល លើកកម្ពស់ឲ្យមានទំនាក់ទំនាក់វិជ្ជាជីវៈប្រកបដោយប្រសិទ្ធភាព តាមរយៈការផ្តល់ជាវេទិកាសម្រាប់កម្មករនិយោជិត និងនិយោជកនៅកម្ពុជា ក្នុងការស្វែងរកដំណោះស្រាយប្រកបដោយយុត្តិធម៌ និងសមធម៌ចំពោះវិវាទការងារដែលកើតមាន។ វិវាទការងារ ត្រូវបានដោះស្រាយដោយផ្ទាល់ និងទាន់ពេលវេលាប្រកបដោយតម្លាភាព តាមរយៈការធ្វើសវនាការ និងការចេញសេចក្តីបង្គាប់ដែលមានយុត្តិធម៌ តុល្យភាព និងមានហេតុផល យោងតាមច្បាប់។

**លោក ម៉ែន និម្មិត** នាយកប្រតិបត្តិមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល មានប្រសាសន៍ថា៖ "ក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើរតួនាទីយ៉ាងសំខាន់ និងសម្រេចបាននូវសមិទ្ធផលគួរឱ្យកត់សម្គាល់ជាច្រើន រួមចំណែកជួយដល់ផ្នែកសង្គមកិច្ច និងសេដ្ឋកិច្ចជាតិ ព្រមទាំងទទួលបានកេរ្តិ៍ឈ្មោះ និងការទទួលស្គាល់ថ្នាក់ជាតិ និងអន្តរជាតិក្នុងការដោះស្រាយវិវាទការងារកន្លងមក។" លោក ម៉ែន និម្មិត មានប្រសាសន៍បន្តថា៖ "មកទល់នឹងឆ្នាំ២០១៩ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល បានទទួលសំណុំរឿងចុះបញ្ជីចំនួន២.៨៨២ករណីដែលមានកម្មករនិយោជិតពាក់ព័ន្ធចំនួនជាង១លាននាក់មកពីវិស័យកាត់ដេរ និងវិស័យផ្សេងៗ នៅទូទាំងប្រទេសកម្ពុជា។ ក្នុងចំណោមសំណុំរឿងដែលបានចុះបញ្ជីទាំងអស់នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល សម្រេចបាននូវអត្រាជោគជ័យក្នុងការដោះស្រាយវិវាទចំនួន៧៥%។ យើងសូមសម្តែងអំណរគុណចំពោះ ម្ចាស់ជំនួយសប្បុរសនានា ដូចជា ទីភ្នាក់ងារសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិសហរដ្ឋអាមេរិក និងប្រទេសស៊ុយអែត ដែលបានជួយគាំទ្រអស់រយៈពេលជាច្រើនឆ្នាំកន្លងមក។"

**លោក និម្មិត** បន្តទៀតថា៖ "យើងក៏សូមថ្លែងអំណរគុណផងដែរចំពោះជំនួយគាំទ្រពីបណ្តាដៃគូអភិវឌ្ឍន៍នានា ប៉ុន្តែយើងមិនភ្លេចពីកាតព្វកិច្ចរបស់មូលនិធិ ដែលត្រូវខិតខំធ្វើឱ្យបានសម្រេចនិរន្តភាពក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលជាអាទិភាពចម្បងទីមួយសម្រាប់មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល៕"

**កំណត់សម្គាល់៖**

- បន្ថែមទៅលើការផ្តល់ជំនួយលើទីមួយ ដើម្បីគាំទ្រដល់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅឆ្នាំ២០១៤ ដោយទីភ្នាក់ងារសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិសហរដ្ឋអាមេរិក រយៈពេលបីឆ្នាំពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៦ និងលើកនេះគឺជាការផ្តល់ជំនួយមូលនិធិសម្រាប់រយៈពេលប្រាំឆ្នាំ ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២៤។ មូលនិធិសរុបទាំងពីរលើកផ្តល់ឱ្យមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលមានចំនួនប្រមាណជាង ២លានដុល្លារសហរដ្ឋអាមេរិក។
- រដ្ឋាភិបាលស៊ុយអែត ដែលបានផ្តល់មូលនិធិគាំទ្រដល់មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលតាំងពីឆ្នាំ២០១៤មក។ ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០២១ រដ្ឋាភិបាលស៊ុយអែតផ្តល់ជំនួយឥតសំណងសរុបចំនួន ១៨លាន ៣សែនក្រូណា ដែលស្មើនឹងចំនួនប្រមាណជា ១លាន៩សែន៨ម៉ឺនដុល្លារសហរដ្ឋអាមេរិក ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃបរិយាកាសអភិបាលកិច្ចទីផ្សារការងារ សម្រាប់ផ្នែកឯកជន និងការអភិវឌ្ឍសង្គម ដោយផ្តល់ឱ្យមានប្រព័ន្ធមជ្ឈត្តវិនិច្ឆ័យដោះស្រាយវិវាទការងារដោយអាជ្ញាកណ្តាលដែលអាចជឿជាក់បាន និងដំណើរការដោយរលូន។

**ទំនាក់ទំនងព័ត៌មាន៖**

**មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល**

លោក ម៉ែន និម្មិត

នាយកប្រតិបត្តិ

អ៊ីម៉ែល៖ nmen@arbitrationcouncil.org

ទូរសព្ទ៖ ០២៣ ៨៨១ ៨១៤

**ស្ថានទូតស៊ុយអែតប្រចាំនៅកម្ពុជា**

លោក សាមូអ៊ែល ហ៊ូទីក

ប្រធានផ្នែកកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិ

ទូរសព្ទ៖ ០២៣ ៨៦១ ៧០០